**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០២០ សព្រក

# សេចក្ដីបញ្ជាក់ព័ត៌មាន

ក្រសួងមហាផ្ទៃ សូមជម្រាបជូនសាធារណជនជ្រាបថា នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥នេះ មានបណ្ដាញព័ត៌មានថៃ បានផ្សព្វផ្សាយថា ពុំមានប្រជាពលរដ្ឋខ្មែរស្លាប់ ក្នុងករណីទាហានថៃបានបើកការបាញ់ប្រហារលើអ្នកភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១២ ខែវិច្ឆិកានោះឡើយ ក្រៅពីជនរងគ្រោះ៣នាក់ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

ក្រសួងមហាផ្ទៃ សូមបញ្ជាក់ជូនថា កម្លាំងប្រដាប់អាវុធថៃ បានបើកការបាញ់ប្រហារដោយប្រើអាវុធវែង ប្រភេទ «M16» ជាច្រើនគ្រាប់មកលើប្រជាពលរដ្ឋខ្មែរ ក្នុងភូមិព្រៃចាន់ បណ្ដាលឱ្យបាត់បង់ជីវិតចំនួន១នាក់ និងរបួសធ្ងន់ចំនួន៣នាក់។ ជនរងគ្រោះបាត់បង់ជីវិត ឈ្មោះ ឌី ណៃ (ហៅសល់) ភេទប្រុស អាយុ៣៦ឆ្នាំ ស្នាក់នៅភូមិព្រៃចាន់។ លទ្ធផលកោសល្យវិច័យរបស់សមត្ថកិច្ចជំនាញកម្ពុជា រកឃើញថា នៅផ្នែកក្បាលនៃសពមានស្នាមដាច់រលាត់ស្បែកមុខ ទំហំ៥មីលីម៉ែត្រ ផ្នែកដងខ្លួនមានស្នាមដាច់ធ្លុះមួយកន្លែងរាងទ្រវែងលើដើមដោះខាងឆ្វេង ទំហំ២គុណនិង៣សង់ទីម៉ែត្រ ទិសដៅបញ្ឆិតចូលក្នុងដងខ្លួនពីឆ្វេងទៅស្ដាំ និងមានក្បាលគ្រាប់កាំភ្លើងបៀមក្រោមស្បែកលើឆ្អឹងជំនីខាងស្ដាំផ្នែកខាងក្រោយចំនួនមួយកន្លែង។ គណៈកម្មការជំនាញបានវះកាត់យកក្បាលគ្រាប់នោះចេញ នៅចំពោះមុខក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ដោយឃើញច្បាស់ថាក្បាលគ្រាប់នោះ មាន០១គ្រាប់ ទំហំមុខកាត់៥.៧មីលីម៉ែត្រគុណបណ្ដោយក្បាលគ្រាប់២៣មីលីម៉ែត្រ មានខ្សែខ្វារីល (រ៉ៃយ៉ា) ចំនួន៦ខ្សែ (វិលស្ដាំ)។

ជាមួយគ្នានេះ គណៈកម្មការកោសល្យវិច័យរកឃើញទៀតថា កន្លែងកើតហេតុទី១ មានប្រជាពលរដ្ឋខ្មែរ៣នាក់រងរបួសធ្ងន់ នៅទីតាំងដែលមានចម្ងាយពីគោលដៅកម្លាំងប្រដាប់អាវុធថៃបាញ់ចេញប្រហែល១០០ម៉ែត្រ។ ឯទី២ ជាទីតាំងជនរងគ្រោះបាត់បង់ជីវិតនៅហ្នឹងកន្លែង ចម្ងាយពីគោលដៅកម្លាំងប្រដាប់អាវុធថៃបាញ់ចេញប្រហែល១៨០ម៉ែត្រ ដោយកម្លាំងប្រដាប់អាវុធថៃ បានបាញ់ចេញពីទីតាំង២កន្លែង ផ្ដោះមកគោលដៅតែមួយ ក្នុងភូមិព្រៃចាន់។

ជារួម ជនរងគ្រោះឈ្មោះ ឌី ណៃ (ហៅសល់) ពិតជាបានស្លាប់ដោយសារការបាញ់ប្រហាររបស់កម្លាំងប្រដាប់អាវុធថៃ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ប្រាកដមែន ពោលគឺមិនដូចការផ្សព្វផ្សាយបំភ្លៃការពិត និងបង្វែរសភាពការណ៍របស់បណ្ដាញព័ត៌មានថៃឡើយ។ ច្បាស់ណាស់ គឺគ្រាប់កាំភ្លើង បានបាញ់ចូលក្នុងធ្លុះសួត ដាច់សសៃឈាមធំៗ និងមានគ្រាប់បៀមនៅផ្នែកខ្នងខាងស្ដាំនៃសព ប្រាកដមែន។

ថ្ងៃសុក្រ ៩រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥

# Statement of Information

The Ministry of Interior would like to inform the public that on this day, November 14, 2025, Thai medias reported that no Cambodian citizen died in the incident which Thai soldiers opened fire on residents of Prey Chan village, Ou Bei Choan commune, Ou Chrov district, Banteay Meanchey province, on November 12, except for the three victims who are currently receiving medical treatment at the hospital.

The Ministry of Interior would like to clarify that the Thai armed forces opened fire using several rounds from long-barreled M16 rifles on Cambodian citizens in Prey Chan village, resulting in one death and three serious casualties. The deceased victim's name is Dy Nai (known as Sal), male, 36 years old, residing in Prey Chan village. The results of the autopsy examination by the Cambodian specialized authorities found that: on the head of the deceased, there was an abrasion (laceration) on the facial skin measuring 5 millimeters; on the torso, there was one elongated penetrating wound on the upper left chest, measuring 2 by 3 centimeters, with a trajectory slanted into the torso from left to right; and there was one bullet lodged beneath the skin over the right ribcage on the posterior side. The medical committee surgically removed the bullet in the presence of the ASEAN Observer Team (AOT). It was clearly observed that there was a bullet, with a diameter of 5.7 millimeters and a length of 23 millimeters. It possessed six helical grooves (rifling) (a right-hand twist).

At the same time, the investigative committee also found that at the first incident site, three Cambodian civilians were seriously injured at a location about 100 meters away from the area where the Thai armed forces fired their weapons. At the second incident site, the victim who lost his life was found about 180 meters away from the area where the Thai armed forces fired. The Thai armed forces had fired from two positions toward a single target in Prey Chan village.

In conclusion, the victim named Dy Nai (known as Sal) was indeed killed by the shooting of the Thai armed forces on November 12, 2025 - contrary to the distortion of the truth and misrepresentation of the situation reported by the Thai media which aimed to mislead the international community. The bullet clearly penetrated and pierced the lungs, severed major blood vessels, and a bullet was indeed lodged in the right posterior side of the deceased's body.

Phnom Penh, November 14, 2025